ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 26-Dec-2014, 10:42
CMS/CFO: Sann Rada

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 002/19-09-2007-ECCC/SC

**នៅចំពោះមុខ៖**
**ចៅក្រម គង់ ស្រីម ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម Agniezska KLONOWIECKAMILART**
**ចៅក្រម ម៉ុង មុន្នីចរិយា**
**ចៅក្រម Florence Ndepele Mwachande MUMBA**
**ចៅក្រម យ៉ា ណារិន**

**កាលបរិច្ឆេទឯកសារ៖** ថ្ងៃទី ២៦/ ខែ ធ្នូ / ឆ្នាំ ២០១៤
**ភាសាដើម៖** ខ្មែរ/អង់គ្លេស
**ចំណាត់ថ្នាក់ឯកសារ៖** សាធារណៈ

# សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីជនជាប់ចោទ នួន ជា**
សុន អរុណ
Victor KOPPE

**<u>ជនជាប់ចោទ</u>**

ខៀវ សំផន

នួន ជា

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Marie GUIRAUD

**<u>សហមេធាវីជនជាប់ចោទ ខៀវ សំផន</u>**

គង់ សំអុន

Anta GUISSÉ

Arthur VERCKEN

១. **អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" និង "អ.វ.ត.ក") បានទទួលសំណើមួយដែលបានដាក់នៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") ដែលបានស្នើសុំការអនុញ្ញាតដាក់សារណាជាលាយលក្ខណ៍អក្សរពាក់ព័ន្ធនឹងសេចក្តីសន្និដ្ឋាននានាលើបណ្តឹងសាទុក្ខរបស់ភាគីផ្សេងៗទៀត ("សំណើសុំ")[1]។

## <u>សាវតារ</u>

២. នៅថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមក្នុងសំណុំរឿង ០០២/០១ ("សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង")[2] ដោយបានផ្តន្ទាទោស ខៀវ សំផន និង នួន ជា ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល (រួមបញ្ចូលទាំង ការធ្វើមនុស្សឃាត) ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស), ហើយដោយបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត[3]។

៣. នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ នួន ជា និង ខៀវ សំផន បានដាក់សេចក្តីជូនដំណឹងស្តីពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដោយ នួន ជា បានដាក់មូលដ្ឋានចំនួន ២២៣ នៃបណ្តឹងសាទុក្ខ ចំណែក ខៀវ សំផន ដាក់មូលដ្ឋានចំនួន ១៤៨ នៃបណ្តឹងសាទុក្ខ[4]។ សហ

---

[1] សំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងបណ្តឹងសាទុក្ខនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ F10។

[2] សាលក្រមលើសំណុំរឿង ០០២/០១ ឯកសារ E313 ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤។

[3] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ទំព័រ ៦២២ (ភាសាអង់គ្លេស)។

[4] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារ E313/1/1 ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤។ *សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីលោក ខៀវ សំផន ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១* ឯកសារ E313/2/1 ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤។ *សូមមើលផងដែរ* សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំពន្យាពេល និងបន្ថែមចំនួនទំព័រលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណានៃបណ្តឹងសាទុក្ខ ឯកសារ F3/3 ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៤។

ព្រះរាជអាជ្ញា ក៏បានដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខនៅថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ ២០១៤ តែនៅលើមូលដ្ឋានតែមួយដែលថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការសម្រេចមិនបញ្ចូលការពិចារណាទៅលើទម្រង់ទីបី នៃសហឧក្រិដ្ឋកម្មរួម ("JCE III") ជាទម្រង់មួយនៃការទទួលខុសត្រូវ[5]។ ដើមបណ្ដឹងរដ្ឋប្បវេណី មិនបានដាក់បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងទេ។

៤. បន្ទាប់ពីមានសំណើមួយចំនួនពីភាគី[6] អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចដោយសង្ខេបថា៖ (១) នួន ជា និង ខៀវ សំផន ត្រូវបានអនុញ្ញាតឲ្យដាក់សារណាបណ្ដឹងសាទុក្ខរបស់ខ្លួន (រួមគ្នាជា "សារណាបណ្ដឹងសាទុក្ខ") ត្រឹមថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤[7], (២) សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា និង ខៀវ សំផន មិនអាចលើសចំនួន ២៧០ ទំព័រសម្រាប់ នួន ជា និងមិនអាចលើសចំនួន ២១០ ទំព័រសម្រាប់ ខៀវ សំផន ជាភាសាអង់គ្លេស ឬភាសាបារាំង ដោយគ្មានការកំណត់ចំនួនទំព័រចំពោះសំណៅជាភាសាខ្មែរទេ[8], (៣) សហព្រះរាជអាជ្ញា ត្រូវបានអនុញ្ញាតឲ្យដាក់សារណាតបរួម មិនឲ្យលើសពី ២៨០ ទំព័រ ដែលត្រូវដាក់ក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងចុងក្រោយបង្អស់នៃការដាក់ឯកសារបកប្រែជាភាសាខ្មែរនៃសារណាបណ្ដឹងសាទុក្ខរបស់ នួន ជា និង ខៀវ

---

[5] សេចក្ដីជូនដំណឹងរបស់សហព្រះរាជអាជ្ញា ស្ដីពីបណ្ដឹងសាទុក្ខចំពោះសេចក្ដីសម្រេច នៅក្នុងសំណុំរឿង ០០២/០១ ឯកសារ E313/3/1 ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤។

[6] សំណើលើកទីពីរសុំពន្យាពេល និងបន្ថែមចំនួនទំព័រសម្រាប់បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ F6 ចុះថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០១៤។ *ការស្នើសុំជាបន្ទាន់របស់លោក ខៀវ សំផន សុំពន្យាពេលកំណត់ និងបង្កើនចំនួនទំព័រ នៅក្នុងសារណាបណ្ដឹងសាទុក្ខ* ឯកសារ F7 ចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១៤។ ចម្លើយតប និងសំណើរបស់សហព្រះរាជអាជ្ញាលើបណ្ដឹងសាទុក្ខសំណុំរឿង ០០២/០១ និងសុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ធ្វើសារណាតប ឯកសារ F7/1 ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤។ *សំណើបន្ទាន់របស់មេធាវីការពារក្ដីលោក ខៀវ សំផន សុំពន្យាពេលឆ្លើយតបទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា* ឯកសារ F12 ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤។ សំណើបន្ទាន់របស់ នួន ជា សុំពេលវេលាបន្ថែមដើម្បីឆ្លើយតបទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ F14 ចុះថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៤។ សំណើបន្ទាន់ សុំការពិចារណាឡើងវិញលើចំនួនទំព័រកំណត់លើបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងរឿងក្ដី ០០២/០១ ឯកសារ F13 ចុះថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៤។

[7] សេចក្ដីសម្រេចលើសំណើសុំពន្យារយៈពេល និងបន្ថែមចំនួនទំព័រ សម្រាប់សារណាបណ្ដឹងសាទុក្ខ និងសារណាតប ឯកសារ F9 ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ("សេចក្ដីសម្រេចលើសំណើសុំពន្យាពេល") កថាខណ្ឌ ២៣។

[8] សេចក្ដីសម្រេចលើសំណើសុំពន្យារយៈពេល កថាខណ្ឌ ២៣។ សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដីសុំបន្ថែមចំនួនទំព័រ ដើម្បីប្ដឹងសាទុក្ខ និងបន្ថែមពេលវេលាដើម្បីដាក់សារណាតប ឯកសារ F13/2, ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៤ ("សេចក្ដីសម្រេចលើកទីពីរ លើសំណើសុំពន្យាពេល") កថាខណ្ឌ ១៧។

សំផន[9], (៤) សារណាតបរបស់មេធាវីការពារក្តីទៅនឹងសារណាបណ្តឹងទុក្ខរបស់សហព្រះរាជអាជ្ញា ត្រូវដាក់ត្រឹមថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០១៥ *មានន័យថា* ៣០ ថ្ងៃ ក្រោយពេលផុតកំណត់កាលបរិច្ឆេទនៃការដាក់សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី[10]។

៥. អង្គជំនុំជម្រះតុលាការកំពូល មិនបានផ្តល់ការពន្យារពេលបន្ថែមដល់សហព្រះរាជអាជ្ញា ក្នុងការដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន[11] ដែលបានដាក់នៅថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៤ ឡើយ ("សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា")[12]។

## សារណា

៦. សហមេធាវីនាំមុខលើកឡើងថា ដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីដែលដាក់ដោយមេធាវីការពារក្តី នួន ជា និង ខៀវ សំផន[13]។ បើទោះជា បញ្ហានេះ ពុំមានចែងក្នុងវិធានផ្ទៃក្នុង[14] និងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ[15] ក៏ដោយ ក៏ដើមបណ្តឹងរដ្ឋប្បវេណី បានទាញការអនុញ្ញាតនេះចេញពីភាពជាក់ស្តែងដែលថា ដើមបណ្តឹងរដ្ឋប្បវេណីគឺជា "ភាគីនៃកិច្ចដំណើរការនីតិវិធី ដែលមានសិទ្ធិដោយឡែកមួយ"[16] ដែលផលប្រយោជន៍របស់ខ្លួន គប្បីត្រូវបានតំណាងពីដើមដល់ចប់នៃកិច្ចដំណើរការនីតិវិធី។ ជាពិសេស សហមេធាវីនាំមុខសង្កេតឃើញថា ទឡ្ហីករណ៍មួយចំនួនធំ ដែលបានលើកឡើងនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី គឺពាក់ព័ន្ធដោយផ្ទាល់នឹងភស្តុតាង ដែលដើមបណ្តឹងរដ្ឋប្បវេណី បានបង្ហាញក្នុងដំណាក់កាលជំនុំជម្រះ[17]។

---

9 សេចក្តីសម្រេចលើសំណើសុំពន្យាពេល កថាខណ្ឌ ២៣។

10 សេចក្តីសម្រេចលើកទីពីរ លើសំណើសុំពន្យាពេល កថាខណ្ឌ ១៧។

11 សេចក្តីសម្រេចលើសំណើសុំពន្យាពេល កថាខណ្ឌ ១៤។

12 បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១ ឯកសារ F11 ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤។

13 សំណើ កថាខណ្ឌ ១, ១២។

14 វិធានផ្ទៃក្នុង អ.វ.ត.ក វិសោធនកម្មលើកទី ៨ ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១១ ("វិធានផ្ទៃក្នុង")។

15 សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក វិសោធនកម្មលើកទី ៨ ថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១២ ("សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ")។

16 សំណើ កថាខណ្ឌ ២, ៨។ *សូមមើលផងដែរ* សំណើ កថាខណ្ឌ ១០។

17 សំណើ កថាខណ្ឌ ១៣ ដល់ ១៨។

៧. សហមេធាវីនាំមុខលើកឡើងបន្ថែមទៀតថា ដើមបណ្តឹងរដ្ឋប្បវេណី "រក្សាសិទ្ធិ" ក្នុងការដាក់សារណា ដើម្បីបញ្ជាក់នូវជំហររបស់ខ្លួនទៅលើសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា[18]។

៨. ចុងក្រោយ ដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំការពន្យារពេលគ្រប់គ្រាន់ និងការបន្ថែមចំនួនទំព័រជាមួយនឹងការស្នើសុំដាក់សារណាជាលាយលក្ខណ៍អក្សររបស់ខ្លួនតែមួយភាសាគត់ ដោយសារការអនុញ្ញាតនេះ បានផ្តល់ឲ្យភាគីដទៃទៀត នៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលស្តីពីការសម្រេចលើសំណើសុំពន្យារពេល[19]។ ជាពិសេស សហមេធាវីនាំមុខ ស្នើសុំបន្ថែមចំនួន ៦០ ទំព័រ ចំពោះសារណាតបរួមរបស់ខ្លួន ដោយសុំការអនុញ្ញាតដាក់ក្នុងរយៈពេល ៣០ ថ្ងៃគិតចាប់ពីថ្ងៃទទួលបានការជូនដំណឹងចុងក្រោយបង្អស់ នូវឯកសារបកប្រែជាភាសាខ្មែរនៃសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី[20]។

៩. នៅក្នុងសារណាតបរបស់ខ្លួន[21] នួន ជា លើកពីបញ្ហានៃ "ការសន្មតជាមុនយ៉ាងច្បាស់" របស់សហមេធាវីនាំមុខដែលថា ដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិស្មើនឹងភាគីដទៃទៀតក្នុងសំណុំរឿង ០០២ ដែរនោះ[22] ដោយអះអាងថា ជំហរនេះ ផ្ទុយនឹងក្របខណ្ឌច្បាប់ជាធរមាន ហើយវាជាការរំលោភដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលនឹងត្រូវប្រឈមមុខនឹងសហព្រះរាជអាជ្ញាបន្ថែមទៀត[23]។ ហេតុនេះ នួន ជា ស្នើសុំអង្គជំនុំជម្រះតុលាការកំពូល គប្បីប្រកាន់ខ្ជាប់នូវការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែបកស្រាយក្នុងន័យចង្អៀត ហើយថា ដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវទទួលបាន "សិទ្ធិទូទៅក្នុងការចូលរួម ដូចគ្នាទៅនឹងសហព្រះរាជអាជ្ញា"ឡើយ ដូចដែលមានចែងក្នុងវិធាន

---

[18] សំណើ កថាខណ្ឌ ២, ២០, ២១។

[19] សំណើ កថាខណ្ឌ ២២ ដល់ ៣៥។

[20] សំណើ កថាខណ្ឌ ២៧, ៣២, ៣៤។

[21] សារណាតបរបស់ នួន ជា ទៅនឹងសំណើរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារ F10/1 ចុះថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១៤ ("ចម្លើយតប")។

[22] សារណាតប កថាខណ្ឌ ២។

[23] សារណាតប កថាខណ្ឌ ៣, ៥។

២៣(១) នៃវិធានផ្ទៃក្នុង[24]។ ហេតុនេះ នួន ជា អះអាងថា អង្គជំនុំជម្រះតុលាការកំពូល គប្បីបដិសេធសំណើ ហើយមិនត្រូវអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើការឆ្លើយតបឡើយ[25]។ ក្នុងករណីដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឱ្យឆ្លើយតបនោះ នួន ជា ស្នើសុំថា ខ្លឹមសារនៃសំណើរបស់ពួកគេ គប្បីត្រូវបានពិចារណាក្នុងន័យចង្អៀត ហើយមេធាវីការពារក្តី គប្បីត្រូវបានផ្តល់នូវការពន្យារពេលឱ្យមានលក្ខណៈសមាមាត្រមួយ ដើម្បីរៀបចំទឡ្ហីករណ៍ផ្ទាល់មាត់របស់ខ្លួន[26]។

១០. នៅក្នុងការចម្លើយតប[27] សហមេធាវីនាំមុខទទួលស្គាល់ថា តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីខុសពីតួនាទីរបស់សហព្រះរាជអាជ្ញា ប៉ុន្តែនៅតែលើកឡើងថា ពួកគេមាន "តួនាទីស្មើ"[28] បើយោងតាមខ្លឹមសារនៃលក្ខណៈសម្បត្តិជាភាគីនៅក្នុងវិធានផ្ទៃក្នុង។ តាមទស្សនៈរបស់ខ្លួន ដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា ហេតុនេះ សិទ្ធិរបស់ខ្លួន ក្នុងឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី គប្បីត្រូវបានទទួលស្គាល់"ឱ្យបានច្រើន ដោយសារវាប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍ [របស់ដើមបណ្តឹងរដ្ឋប្បវេណី]" ដែលកើតចេញពីសិទ្ធិ ក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះ[29]។

---

[24] សារណាតប កថាខណ្ឌ ៣, ៤ (ដោយដកស្រង់ "សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យចេញសេចក្តីសម្រេចអំពីសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងសេចក្តីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីដែលបានកោះហៅ ឱ្យផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ" របស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ E72/3 ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៩ ("សេចក្តីសម្រេចលើតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី"))។

[25] សំណើ កថាខណ្ឌ ៥។

[26] សំណើ កថាខណ្ឌ ៦។

[27] ការឆ្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទៅនឹងចម្លើយតបរបស់មេធាវីការពារក្តីលោក នួន ជា ទៅនឹងសំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១ ឯកសារ F10/1/1 ចុះថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១៤ ("ការឆ្លើយតប")។

[28] ការឆ្លើយតប កថាខណ្ឌ ៤, ៦។

[29] ការឆ្លើយតប កថាខណ្ឌ ៧, ៨។

## **ការពិភាក្សា**

### ***សំណើសុំដាក់ចម្លើយតបរួមទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី***

១១. ជាដំបូង អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា ជាការពិតណាស់ថា "ជនរងគ្រោះនៅចំពោះមុខ អ.វ.ត.ក មានឋានៈជាភាគី"[30]។ ដូចដែលបានបញ្ជាក់នៅក្នុងសាលដីកាក្នុងសំណុំរឿង ០០១ ដើមបណ្តឹងរដ្ឋប្បវេណី ទទួលបាន"សិទ្ធិចូលរួមយ៉ាងពេញលេញដែលដើមបណ្តឹងរដ្ឋប្បវេណីមានផ្អែកតាមក្រមនីតិវិធីព្រហ្មទណ្ឌ[កម្ពុជា] និងវិធានផ្ទៃក្នុង នៅមុនដំណាក់កាលជំនុំជម្រះ ក្នុងដំណាក់កាលជំនុំជម្រះ និងក្នុងដំណាក់កាលបណ្តឹងសាទុក្ខ"[31]។ តែទោះបីជាយ៉ាងណាក៏ដោយ គប្បីធ្វើការកត់សម្គាល់ដែលថា ភាគីនីមួយៗ មានដូចជា"សហព្រះរាជអាជ្ញា ជនត្រូវចោទ/ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី"[32] ត្រូវបានផ្តល់សិទ្ធិចូលរួមក្នុងនីតិវិធីខុសៗគ្នាទៅតាមមុខងារ និងការទទួលខុសត្រូវជាក់លាក់របស់ខ្លួននៅក្នុងកិច្ចដំណើរការនីតិវិធី[33]។

១២. អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា ទោះបីជាវិធានផ្ទៃក្នុង ចែងយ៉ាងជាក់លាក់នូវសិទ្ធិចូលរួមមួយចំនួនក៏ដោយ ក៏វិធាននេះ ពុំមានចែងអំពីករណីថា តើដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ភាគីដទៃទៀត ដែរ ឬ យ៉ាងណា នោះឡើយ។ ដូច្នេះ បញ្ហានេះ ត្រូវដោះស្រាយតាមរយៈការវិភាគនិយាមទូទៅស្តីពីការចូលរួមរបស់ជនរងគ្រោះនៅ អ.វ.ត.ក ព្រមទាំងវិធានពិសេសៗ ដែលបានផ្តល់នូវបុព្វសិទ្ធិជាក់លាក់ ដល់ដើមបណ្តឹងរដ្ឋប្បវេណី។ ពាក់ព័ន្ធនឹងករណីនេះ ចាំបាច់ត្រូវគោរពតាមវិធាន ២៣(១) នៃវិធានផ្ទៃក្នុង ដែលកំណត់អំពីគោលបំណងនៃការចូលរួមរបស់ជនរងគ្រោះ នៅក្នុងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ទៅលើទិដ្ឋភាពចំនួនពីរ៖ ជាទូទៅ ក្នុងគោលបំណងដើម្បី"គាំទ្រស្ថាប័នអយ្យការ"[34] ក៏ប៉ុន្តែ ក៏"មានទំនាក់ទំនងដែលមិនអាចដាច់ចេញពីគ្នាបានជាមួយនឹងបណ្តឹងរដ្ឋប្បវេណីផងដែរ"[35]។ ការ

---

[30] សាលដីកា F28 ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ("សាលដីកា") កថាខណ្ឌ ៤៨៨ (លេខយោងជើងទំព័រត្រូវបានលុបចោល)។ *សូមមើលផងដែរ* វិធាន ២៣(៣) នៃវិធានផ្ទៃក្នុង។

[31] សាលដីកា កថាខណ្ឌ ៤៧៨។

[32] សទ្ទានុក្រមនៃវិធានផ្ទៃក្នុង (វិ.លើកទី ៨) *ពាក្យ* "ភាគី"។

[33] *សូមមើល* សេចក្តីសម្រេចលើឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ២៧។

[34] វិធាន ២៣(១)(ក) នៃវិធានផ្ទៃក្នុង។

[35] សាលដីកា កថាខណ្ឌ ៤១១។ *សូមមើលផងដែរ* សាលដីកា កថាខណ្ឌ ៤៨៩។

ពិភាក្សានាពេលនេះ គឺជាប់ពាក់ព័ន្ធនឹងទិដ្ឋភាពនៃ“ការគាំទ្រស្ថាប័នអយ្យការ” ដែលបញ្ជាក់យ៉ាងជាក់លាក់ថា ទីមួយ បណ្តឹងរដ្ឋប្បវេណី គឺជាបណ្តឹងរណប ពោលគឺពុំមែនបណ្តឹងមួយផ្សេងពីបណ្តឹងរបស់សហព្រះរាជអាជ្ញានោះទេ ហើយ ទីពីរ សិទ្ធិចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបកស្រាយឱ្យស្រប និងដើម្បីផ្តល់អនុភាពសម្រាប់គោលបំណងនេះ។ ក្នុងពេលជាមួយគ្នានេះដែរ វិធាន ២១(១)(ក) ចែងថា តុលាការត្រូវធានានូវតុល្យភាពនៃសិទ្ធិរបស់ភាគីនានា។ នៅក្នុងន័យនេះ ជាការចាំបាច់ដែលថា ការបកស្រាយក្នុងន័យទូលាយលើបុព្វសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវឱ្យរំលោភលើសិទ្ធិមូលដ្ឋានរបស់ជនជាប់ចោទ, រារាំងដល់ការបំពេញមុខងាររបស់ស្ថាប័នអយ្យការ ឬប៉ះពាល់ដល់ការប្រព្រឹត្តទៅនៃកិច្ចដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធភាពនោះទេ។

១៣. ស្របជាមួយនឹងការអះអាងទាំងនេះ ជាធម្មតា វិធានផ្ទៃក្នុង ចាត់ទុកដើមបណ្តឹងរដ្ឋប្បវេណីថា ជាអ្នកមានបុព្វសិទ្ធិជាក់លាក់[36] ប៉ុន្តែ ពេលខ្លះ វិធានផ្ទៃក្នុងនេះ ចែងរិតត្បិតជាក់លាក់អំពីសិទ្ធិរបស់ពួកគេទៅវិញ[37]។ ក្នុងចំណោមការកម្រិតសិទ្ធិទាំងនេះដែលគួរឱ្យកត់សម្គាល់នោះគឺថា ទោះបីជាវិធានផ្ទៃក្នុង បានផ្តល់សិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក៏ដោយ ក៏សិទ្ធិនេះ អាចត្រូវបានអនុវត្តត្រឹមតែករណីដូចខាងក្រោមប៉ុណ្ណោះ:

> “ដើមបណ្តឹងរដ្ឋប្បវេណី អាចដាក់ពាក្យបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចស្តីពីសំណង។ នៅពេលដែលសហព្រះរាជអាជ្ញា បានធ្វើបណ្តឹងសាទុក្ខរួចហើយ ដើមបណ្តឹងរដ្ឋប្បវេណីអាច ដាក់ពាក្យបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម។ ដើមបណ្តឹងរដ្ឋប្បវេណីមិនអនុញ្ញាតឱ្យធ្វើបណ្តឹងសាទុក្ខលើសេចក្តីសម្រេចផ្តន្ទាទោសបានឡើយ”[38]។

---

[36] *សូមមើល ឧ.* វិធាន ២៣(៣) និងវិធាន ២៣*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង (សិទ្ធិតំណាងដោយមេធាវី)។ វិធាន ២៣(៤) វិធាន ២៣*ស្ទួនពីរ* (២) និងវិធាន ៥៩ នៃវិធានផ្ទៃក្នុង (សិទ្ធិត្រូវបានសាកសួរដោយមានវត្តមានមេធាវី)។ វិធាន ៥៥(១០) និងវិធាន ៥៩(៥) នៃវិធានផ្ទៃក្នុង (សិទ្ធិស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរ)។ វិធាន ៨០(២) នៃវិធានផ្ទៃក្នុង (សិទ្ធិដាក់បញ្ជីសាក្សី)។ វិធាន ៩៤(១)(ក) និង(២) នៃវិធានផ្ទៃក្នុង (សិទ្ធិធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល និងសេចក្តីសន្និដ្ឋានឆ្លើយតប)។

[37] *សូមមើល ឧ.* វិធាន ៧៤(៤) នៃវិធានផ្ទៃក្នុង (បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត)។ វិធាន ៨២ នៃវិធានផ្ទៃក្នុង (ការឃុំខ្លួនបណ្តោះអាសន្ន និងការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ)។ វិធាន ៨៩*ស្ទួន*(២) នៃវិធានផ្ទៃក្នុង (សេចក្តីដ្ឋានបើកការចោទប្រកាន់)។ វិធាន ១០៥(១)(គ) នៃវិធានផ្ទៃក្នុង (បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៃអង្គជំនុំជម្រះសាលាដំបូង)។

[38] វិធាន ១០៥(១)(គ) នៃវិធានផ្ទៃក្នុង។ សិទ្ធិប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង គឺជាសិទ្ធិតែមួយគត់ដែលបានផ្តល់ជូនយ៉ាងជាក់លាក់ដល់ជនរងគ្រោះនៅក្នុងលិខិតុបករណ៍បង្កើត អ.វ.ត.ក៖ *សូមមើល* ច្បាប់ស្តីពីការ

ទោះបីជាមានការរិតត្បិតយ៉ាងណាក៏ដោយ ក៏សិទ្ធិនេះ នៅតែមានលក្ខណៈទូលំទូលាយជាង សិទ្ធិដែលមានចែងនៅក្នុងក្រមនីតិវិធី ព្រហ្មទណ្ឌកម្ពុជា និងក្រមនីតិវិធីដើមរបស់បារាំង ដែលប្រទេសកម្ពុជាយកលំនាំតាម។ ក្រមទាំងនោះចែងថា ដើមបណ្ដឹងរដ្ឋប្បវេណី អាចប្ដឹងសាទុក្ខលើ "បញ្ហារដ្ឋប្បវេណីនៃរឿងក្ដី" តែមួយគត់[39]។

១៤. អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ទោះបីជាបទប្បញ្ញត្តិជាធរមាន ជាទូទៅ បានផ្ដល់ឲ្យ"ភាគី"នូវបុព្វសិទ្ធិនីតិវិធីក៏ដោយ ក៏បុព្វសិទ្ធិនេះ គប្បីត្រូវបានសន្មតថា មានចំពោះគ្រប់ភាគីទាំងអស់នៅក្នុងការជំនុំជម្រះ ដរាបណា ពុំមានការចែងជាក់លាក់អំពីមុខងាររបស់ភាគី និងពុំមានការរិតត្បិតជាក់លាក់នោះឡើយ។ ឧទាហរណ៍ ករណីនេះ អនុវត្តលើសិទ្ធិក្នុងការលើកឡើង និងការស្ដាប់របស់តុលាការ[40] និងសិទ្ធិក្នុងការសួរជនជាប់ចោទ សាក្សី និងអ្នកជំនាញ[41]។ នៅក្នុងរឿងក្ដីបច្ចុប្បន្ន អង្គជំនុំជម្រះតុលាការកំពូល យល់ស្របជាមួយនឹងសហមេធាវីនាំមុខត្រង់ចំណុចថា ដរាបណាទឡ្ហីករណ៍នៅក្នុងសារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី ប៉ះពាល់ដល់ផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី សិទ្ធិខ្លួនក្នុងការជំទាស់ទៅនឹងបណ្ដឹងសាទុក្ខនេះកើតចេញយ៉ាងសមហេតុផលពីបុព្វសិទ្ធិដែលបានផ្ដល់ឱ្យដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងដំណាក់កាលស៊ើបអង្កេត ដំណាក់កាលជំនុំជម្រះ និងដំណាក់កាលបណ្ដឹងសាទុក្ខ។ ជាពិសេស អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា "ភាគី" មានសិទ្ធិ ធ្វើសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ នៅចំពោះមុខអង្គជំនុំជម្រះ ដែលមានសមត្ថកិច្ច រហូតដល់ពេលដាក់សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញ

---

បង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១០ ជាមួយនឹងវិសោធនកម្មដូចបានប្រកាសនៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ (NS/RKM/1004/006) ("ច្បាប់ អ.វ.ត.ក") មាត្រា ៣៦ ថ្មី។

[39] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ("ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា") មាត្រា ៣៧៥។ ក្រមនីតិវិធីព្រហ្មទណ្ឌនៃសាធារណរដ្ឋបារាំង មាត្រា ៤៩៧ ("សិទ្ធិប្ដឹងឧទ្ធរណ៍/សាទុក្ខគឺជាសិទ្ធិរបស់ (...) ដើមបណ្ដឹងរដ្ឋប្បវេណីទាក់ទងនឹងបណ្ដឹងទាមទារសំណងតែប៉ុណ្ណោះ")។ *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៣៧២ មាត្រា ៤០២ *សូមអានផ្ទួបជាមួយនឹង*ច្បាប់នីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៣ មាត្រា ១៦១ (សិទ្ធិប្ដឹងឧទ្ធរណ៍ដោយគ្មានការរិតត្បិត យោងតាម "ការទាមទារសំណងរបស់ដើមបណ្ដឹង")។

[40] វិធាន ៨៨(១) និងវិធាន ៩១(១) នៃវិធានផ្ទៃក្នុង (សិទ្ធិស្ដាប់ចម្លើយ)។ វិធាន ៨៩(២) នៃវិធានផ្ទៃក្នុង (សិទ្ធិឆ្លើយតបទៅនឹងអញ្ញត្រកម្ម), វិធាន ៩២ នៃវិធានផ្ទៃក្នុង (សិទ្ធិក្នុងការធ្វើសារណាជាលាយលក្ខណ៍អក្សរ)។

[41] វិធាន ៩០(២) វិធាន ៩១(២) នៃវិធានផ្ទៃក្នុង។

ដោយ[42] ដូចមាន ចែងយ៉ាងលម្អិតនៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ។ ការអនុញ្ញាតឱ្យដាក់បណ្តឹង និងសារណាជាលាយលក្ខណ៍អក្សរ រួមបញ្ចូលយ៉ាងសមហេតុផលនូវសិទ្ធិដាក់សារណាតប និងការឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានរបស់ភាគីមួយទៀត ដែលស្របទៅតាមក្របខណ្ឌនៃកិច្ចដំណើរការនីតិវិធីចំពោះមុខ។ ដូច្នេះ ការមិនទទួលស្គាល់សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី នៅក្នុងដំណាក់កាលនេះ គឺជាការមិនស្របទៅនឹងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងនឹងតួនាទីជាទូទៅរបស់ពួកគេ នៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនិតិវិធី។

១៥. ដើម្បីឆ្លើយតបទៅនឹងការអះអាងរបស់ នួន ជា ដែលថា "ការសន្មតជាមុនយ៉ាងច្បាស់"[43] របស់សហមេធាវីនាំមុខដែលថា ដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិស្មើគ្នាជាមួយនឹងភាគីផ្សេងទៀតនៅក្នុងសំណុំរឿង ០០២ "គឺផ្ទុយគ្នាយ៉ាងច្បាស់ក្រឡែត"ទៅនឹងក្របខណ្ឌគតិយុត្តជាធរមាននោះ[44] អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ពុំមានការបង្ហាញណាមួយនៅក្នុងសំណើសុំ ឬការឆ្លើយតបរបស់សហមេធាវីនាំមុខដែលលើកឡើងថា ការយល់របស់ខ្លួនអំពីក្របខណ្ឌចូលរួមរបស់ជនរងគ្រោះ បញ្ជាក់នូវភាពស្មើគ្នារវាងតួនាទីរបស់ដើមណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញានោះឡើយ[45]។ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់*ខាងលើ*រួចហើយថា សំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី បានផ្អែកតាមអំណះអំណាងដែលថា ក្នុងនាមជាភាគីនៃកិច្ចដំណើរការនីតិវិធី គឺមានន័យថា ជាការទទួលបានសិទ្ធិទាំងអស់ដែលត្រូវបានផ្តល់ជាទូទៅដល់ "ភាគី" ដោយអនុលោមតាមគោលការណ៍ និងវិធានជាធរមាន ដោយមានការបញ្ជាក់ដែលសហមេធាវីនាំមុខបានទទួលស្គាល់យ៉ាងច្បាស់រួចហើយថា[46] អាស្រ័យទៅតាមមុខងារផ្សេងៗគ្នា ភាគីនីមួយៗមានសិទ្ធិខុសៗគ្នា ក្នុងការចូលរួមនៅក្នុងកិច្ចដំណើរការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌ។

១៦. ដូចគ្នានេះដែរ ការយោងលើច្បាប់ និងការអនុវត្តរបស់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀតពុំមានលក្ខណៈសមស្របនោះទេ ជាពិសេស តុលាការព្រហ្មទណ្ឌអន្តរជាតិ ("តុលាការ ICC")[47]។

[42] វិធាន ៩២ វិធាន ១០៤*ស្ទួន* នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៣៩១។

[43] សារណាតប កថាខណ្ឌ ២។

[44] សារណាតប កថាខណ្ឌ ៣។

[45] *សូមមើល* សំណើសុំ កថាខណ្ឌ ៨-១២។ ការឆ្លើយតប កថាខណ្ឌ ៤ ៦។

[46] ការឆ្លើយតប កថាខណ្ឌ ៦។

[47] សារណាតប កថាខណ្ឌ ៣ និងលេខយោងជើងទំព័រ ៨។

ទោះបីជាជនរងគ្រោះនៅតុលាការ ICC មានសិទ្ធិទូទៅ និងស្វយ័តក្នុងការឆ្លើយតបក៏ដោយ[48] ក៏សាលដីកានៅក្នុងសំណុំរឿង ០០១ បានបញ្ជាក់ច្បាស់រួចហើយថា ដោយសារ "លក្ខណៈខុសគ្នាជាមូលដ្ឋាន" រវាងក្របខណ្ឌចូលរួមរបស់ជនរងគ្រោះនៅ អ.វ.ត.ក និងនៅតុលាការ ICC ហេតុដូច្នេះ គោលការណ៍ណែនាំតិចតួចតែប៉ុណ្ណោះ ប្រសិនបើមាន អាចស្វែងរកបានពីតុលាការ ICC នេះបាន ដែលចែងថា "ជនរងគ្រោះ ពុំមានឋានៈជាភាគីនៃកិច្ចដំណើរការនីតិវិធីនោះទេ ប៉ុន្តែមានឋានៈពិសេស "[49]។ យោងតាមឋានៈនេះ ដើម្បីបំពេញតួនាទីរបស់ខ្លួននៅក្នុងកិច្ចដំណើរការនីតិវិធី ជនរងគ្រោះ ទៅតាមករណីជាក់ស្តែង តម្រូវឱ្យបង្ហាញថា មានការប៉ះពាល់ដល់"ផលប្រយោជន៍ផ្ទាល់ខ្លួន"របស់ពួកគាត់[50]។

១៧. ពោលគឺ អង្គជំនុំជម្រះតុលាការកំពូលពិចារណាថា ទោះបីជាពុំមានភាពផ្ទុយគ្នាជាគោលការណ៍រវាងសិទ្ធិក្នុងការឆ្លើយតប និងគោលបំណងនៃការចូលរួមរបស់ជនរងគ្រោះក៏ដោយ ក៏សិទ្ធិដែលបានលើកឡើងនេះ ត្រូវតែបកស្រាយក្នុងគោលបំណង ដើម្បីធ្វើឱ្យស៊ីសង្វាក់គ្នាជាមួយនឹងតួនាទីបន្ទាប់បន្សំរបស់ដើមបណ្តឹងរដ្ឋប្បវេណី *ដោយប្រៀបធៀបនឹង*តួនាទីរបស់សហព្រះរាជអាជ្ញា។ លើសពីនេះទៀត ដោយពិចារណាអំពីតម្រូវការក្នុងការការពារសមភាពនៃមធ្យោបាយតទល់ក្តីគ្នា

---

[48] បទប្បញ្ញត្តិនៃតុលាការ [ព្រហ្មទណ្ឌអន្តរជាតិ] (ដែលបានអនុម័តនៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៤ ICC-BD/01-01-04) បទប្បញ្ញត្តិ ២៤(១) និង (២)។

[49] សាលដីកា កថាខណ្ឌ ៤៧៨ ៤៨៦។

[50] លក្ខន្តិកៈនៃតុលាការ ICC មាត្រា ៦៨(៣)។ វិធាន ៨៩(១) នៃវិធានស្តីពីនីតិវិធី និងភ័ស្តុតាងនៃតុលាការ ICC។ *សូមមើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Laurent Gbagbo* ICC-02/11-01/11 "សំណៅក្រែប្រែលើសេចក្តីសម្រេចលើកទីពីរស្តីពីការចូលរួមរបស់ជនរងគ្រោះនៅក្នុងដំណាក់កាលនៃសវនាការតម្កល់បទចោទ និងនៅក្នុងដំណាក់កាលនៃដំណើរការនីតិវិធីពាក់ព័ន្ធនានា" អង្គបុរេជំនុំជម្រះ I ចុះថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ ៥៩។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Katanga និង Chui* ICC-01/04-01/07-2288 "សាលដីកាលើបណ្តឹងសាទុក្ខរបស់លោក Katanga ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង II ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១១ ចំណងជើងថា "សេចក្តីសម្រេចលើទម្រង់ចូលរួមរបស់ជនរងគ្រោះនៅក្នុងដំណាក់កាលជំនុំជម្រះ" អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៣៩។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo* ICC-01/04-01/06-1119 "សេចក្តីសម្រេចលើការចូលរួមរបស់ជនរងគ្រោះ" អង្គជំនុំជម្រះសាលាដំបូង I ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨ កថាខណ្ឌ ៩៦ ("ដើម្បីចូលរួមនៅក្នុងដំណាក់កាលជាក់លាក់ណាមួយនៅក្នុងកិច្ចដំណើរការនីតិវិធីបាន (...) ជនរងគ្រោះតម្រូវឱ្យបង្ហាញនៅក្នុងសំណើសុំជាលាយលក្ខណ៍ជាក់លាក់អំពីហេតុផលដែលផលប្រយោជន៍របស់ខ្លួនត្រូវបានប៉ះពាល់តាមរយៈភ័ស្តុតាង ឬបញ្ហាដែលលេចឡើងនៅក្នុងរឿងក្តីនាពេលនោះ និងលក្ខណៈ និងវិសាលភាពនៃការចូលរួមដែលពួកគេស្នើសុំ។ ផលប្រយោជន៍ទូទៅនៅក្នុងពេលបញ្ចប់រឿងក្តី ឬនៅក្នុងបញ្ហា ឬភស្តុតាងទាំងឡាយដែលអង្គជំនុំជម្រះនឹងពិចារណានៅក្នុងដំណាក់កាលនោះទំនងជាពុំគ្រប់គ្រាន់ឡើយ")។

និងក្តីបារម្ភនានាទាក់ទិននឹងការរៀបចំកិច្ចដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធភាពនោះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការអនុវត្តសិទ្ធិក្នុងការឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ត្រូវតែស្ថិតនៅក្រោមដែនកំណត់។ ទីមួយ ទឡ្ហីករណ៍ដែលបានលើកឡើងនៅក្នុងសារណាតបដែលបានស្នើឡើង ត្រូវតែទាក់ទិនទៅនឹងមូលហេតុនានា ដែលប៉ះពាល់ដោយផ្ទាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី។ ទីពីរ សហមេធាវីនាំមុខត្រូវតែព្យាយាមបញ្ចៀសនូវភាពច្រំដែល និងភាពជាន់គ្នាទៅលើបញ្ហានានា ដែលមានរួចហើយនៅក្នុងសារណាតប ដែលសហព្រះរាជអាជ្ញាបានគ្រោងរៀបចំឡើងប្រឆាំងទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលសម្រេចកំណត់កាលបរិច្ឆេទសម្រាប់ដាក់សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី បន្ទាប់ពីការជូនដំណឹងអំពីសារណាតបរបស់សហព្រះរាជអាជ្ញា ដូចមានបញ្ជាក់ខាងក្រោម។

១៨. ក្នុងករណីដែលសំណើសុំដាក់សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានអនុញ្ញាតនោះហើយ នួន ជា ស្នើសុំពេលវេលាបន្ថែម ដើម្បីរៀបចំទឡ្ហីករណ៍ផ្ទាល់មាត់របស់គាត់[51]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ពេលវេលាដែលផ្តល់ឱ្យមេធាវីការពារក្តីនៅក្នុងដំណាក់កាលបណ្តឹងសាទុក្ខ គប្បីសមាមាត្រទៅនឹងទំហំ និងភាពស្មុគស្មាញនៃរឿងក្តី ព្រមទាំងវិសាលភាពនៃអំណះអំណាងតបដែលមេធាវីការពារក្តីត្រូវប្រឈមមុខ។ ដូច្នេះ អង្គជំនុំជម្រះ ត្រូវពិចារណាលើចំណុចនេះ បន្ទាប់ពីមានការដាក់សារណាតបនេះ នៅពេលចេញដីកាកំណត់កាលបរិច្ឆេទសវនាការ។

***<u>សំណើសុំពន្យារពេលដើម្បីឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី</u>***

១៩. សហមេធាវីនាំមុខស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូល៖ (i) អនុញ្ញាតឱ្យមានការដាក់សារណាតបរួមទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ក្នុងរយៈពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីសារណានេះជាភាសាខ្មែរ (ii) អនុញ្ញាតឱ្យមានការបន្ថែមចំនួន ៦០ទំព័រទៀតសម្រាប់សារណាតបរួមរបស់ខ្លួនជាភាសាអង់គ្លេស ឬភាសាបារាំង និង (iii) អនុញ្ញាតឱ្យមានការដាក់សារណាតបរួមជាភាសាអង់គ្លេស ឬភាសាបារាំងជាមុនសិន ដោយសំណៅបកប្រែជាភាសាខ្មែរនឹងត្រូវដាក់តាមក្រោយភ្លាមៗតាមដែលអាចធ្វើទៅបាន។

---

[51] សារណាតប កថាខណ្ឌ ៦(ខ)។

២០. យោងតាមសេចក្តីសម្រេចលើសំណើសុំពន្យារពេល ការដាក់សារណាតបរួមរបស់សហព្រះរាជអាជ្ញា ត្រូវបានកំណត់ក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីសារណាបណ្តឹងសាទុក្ខចុងក្រោយណាមួយជាភាសាខ្មែររបស់ នួន ជា និង ខៀវ សំផន[52]។ ដូចដែលបានបញ្ជាក់រួចហើយ អង្គជំនុំជម្រះតុលាការកំពូលមានបំណងផ្តល់ឱកាសឲ្យដើមបណ្តឹងរដ្ឋប្បវេណីរៀបចំសារណាតបរួមមួយ ដែលមិនមានភាពច្រំដែល ឬជាន់គ្នាទៅលើបញ្ហានានាដែលរៀបចំឡើងដោយសហព្រះរាជអាជ្ញា។ ដូច្នេះ ដោយពិចារណាទៅលើការប្រមើលមើលអំពីវិសាលភាពនៃសារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី[53] និងដោយពិចារណាអំពីភាពស្មុគស្មាញក្នុងការតំណាងឲ្យក្រុមជនរងគ្រោះដ៏ធំ និងផ្សេងៗគ្នានោះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា រយៈពេល ៣០ថ្ងៃ ដែលសហមេធាវីនាំមុខបានស្នើឡើងនោះ គឺមានលក្ខណៈសមហេតុផល ប៉ុន្តែ ត្រូវចាប់ផ្តើមគិតចាប់ពីថ្ងៃជូនដំណឹងអំពីសារណាតបរបស់សហព្រះរាជអាជ្ញាជាភាសាផ្លូវការណាមួយរបស់ អ.វ.ត.ក[54]។

## ***សំណើសុំដាក់សារណាតបតែមួយភាសាជាមុនសិន អនុលោមតាមមាត្រា ៧.២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ***

២១. ទាក់ទិននឹងសំណើពាក់ព័ន្ធរបស់សហមេធាវីនាំមុខស្នើសុំដាក់សារណាតបតែមួយភាសានោះ អង្គជំនុំជម្រះតុលាការកំពូល រក្សាការសម្រេចថ្មីៗរបស់ខ្លួនដែលថា ដោយសារតែ "ការលំបាកដែលនៅតែមាននៅក្នុងអង្គភាពបកប្រែភាសា"[55] កាលៈទេសៈពិសេសសម្រាប់អនុវត្តមាត្រា ៧.២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ ត្រូវបានចាត់ទុកថាបានបំពេញ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងការជាប់ទាក់ទិនគ្នានេះ អង្គជំនុំជម្រះក៏រម្លឹកផងដែរថា សហមេធាវីនាំមុខត្រូវខិតខំ

---

[52] សេចក្តីសម្រេចលើសំណើសុំពន្យាររយៈពេល កថាខណ្ឌ ២៣។

[53] សំណើ កថាខណ្ឌ ១៣-១៨។

[54] វិធាន ៣៩(២) និង (៤) នៃវិធានផ្ទៃក្នុង។ សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ មាត្រា ៨.៥។ ដោយសារតែពេលវេលាកំណត់នេះ ហួសពេលវេលាកំណត់ដែលបានស្នើឡើងដោយសហមេធាវីនាំមុខ (សូមមើល សំណើ កថាខណ្ឌ ២៧) សំណើរបស់ពួកគាត់ស្នើសុំឲ្យចាប់ផ្តើមគិតកាលបរិច្ឆេទ បន្ទាប់ពីទទួលបានការជូនដំណឹងអំពីសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីជាភាសាខ្មែរនោះ លែងមានការចាំបាច់ទៀតហើយ។

[55] សេចក្តីសម្រេចលើសំណើសុំពន្យាររយៈពេល កថាខណ្ឌ ១៩ (យោងទៅលើអនុស្សរណៈពីចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា សំណើរបស់មេធាវីការពារក្តី ខៀវ សំផន សុំឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ដល់ការិយាល័យរដ្ឋបាលឲ្យពង្រឹងសមត្ថភាពរបស់អង្គភាពបកប្រែភាសាជាបន្ទាន់" ឯកសារ E317/1 ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤)។ សូមមើល ផងដែរ ដីកាសម្រេចលើសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ដែលសុំឲ្យពង្រឹងសមត្ថភាពរបស់អង្គភាពបកប្រែ ឯកសារ F8/1 ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤។

ប្រឹងប្រែង "ប្រើប្រាស់ធនធានទាក់ទងនឹងភាសាខ្មែរ ដែលមាននៅក្នុងក្រុមរបស់ខ្លួន បានល្អប្រសើរបំផុតក្នុងការបំពេញការងារឲ្យបានស្របគ្នាជាមួយនឹងអង្គភាពបកប្រែភាសា ក្នុងគោលបំណងពន្លឿនការបកប្រែ" ជាភាសាខ្មែរលើសារណាតបរបស់ខ្លួន[56]។

## ***សំណើសុំបន្ថែមចំនួនទំព័រកំណត់ដើម្បីឆ្លើយតបទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី***

២២. សហមេធាវីនាំមុខស្នើសុំបន្ថែមចំនួន ៦០ទំព័រទៀត ទៅលើចំនួនកំណត់ ៣០ទំព័រ ដូច្នេះរំពឹងថាសារណាតបរួមនោះ សរុបមានចំនួន ៩០ ទំព័រ ជាភាសាអង់គ្លេស។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា យោងតាមសហមេធាវីនាំមុខ ប្រមាណប្រហែលជាមួយភាគបីនៃទឡ្ហីករណ៍បណ្ដឹងសាទុក្ខ ដែលបានលើកឡើងដោយមេធាវីការពារក្ដី ប៉ះពាល់ដល់ផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី[57]។ ទោះបីយ៉ាងណាក៏ដោយ សហមេធាវីនាំមុខទទួលស្គាល់ថា "ក្នុងចំណោមទឡ្ហីករណ៍ទាំងនេះ មានទឡ្ហីករណ៍មួយចំនួនដែលត្រួតគ្នា"[58]។ លើសពីនេះទៀត មូលដ្ឋានមួយចំនួន ដែលទាក់ទិននឹងផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី ទំនងជាត្រូវបានលើកឡើងនៅក្នុងសារណាតបរបស់សហព្រះរាជអាជ្ញា។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថាការបន្ថែមចំនួន ៣០ ទំព័រ ទៀត គឺសមស្របនៅក្នុងកាលៈទេសៈទាំងនេះ។

## ***សំណើសុំដាក់ញត្តិធ្វើអត្ថាធិប្បាយទៅលើសារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា***

២៣. ចុងក្រោយ អង្គជំនុំជម្រះតុលាការកំពូលត្រឡប់ទៅពិនិត្យលើសំណើរបស់សហមេធាវីនាំមុខស្នើសុំ"បញ្ជាក់គោលជំហររបស់ពួកគាត់"ចំពោះសារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់អង្គហេតុដែលថា ដើមបណ្ដឹងរដ្ឋប្បវេណីមិនបានដាក់បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។ ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណី មានបំណងជំទាស់ទៅនឹងទម្រង់នៃការទទួលខុសត្រូវ ជាមួយនឹងសហព្រះរាជអាជ្ញាខ្លួនគប្បីបានដាក់ការជូនដំណឹងអំពីបណ្ដឹងសាទុក្ខ អនុលោមតាមវិធាន ១០៥(១)(គ) និង (៣) អនុលោមទៅតាមពេលវេលាកំណត់ដែលកំណត់ឡើងដោយអង្គជំនុំជម្រះតុលាការកំពូល នៅក្នុង

---

[56] សេចក្ដីសម្រេចលើសំណើសុំពន្យាររយៈពេល កថាខណ្ឌ ១៩។

[57] សំណើ កថាខណ្ឌ ៣០។

[58] សំណើ កថាខណ្ឌ ៣១។

ពេលវេលាពាក់ព័ន្ធ[59]។ លើសពីនេះទៀត "ការបញ្ជាក់" បែបនេះ មិនអាចកំណត់លក្ខណៈថាជាសារណាតបឡើយ ដោយហេតុថា សារណាតបសន្មតទុកជាមុនថា ភាគីដែលដាក់ឯកសារ មានគុណសម្បត្តិជាចុងបណ្តឹងសាទុក្ខទល់នឹងសហព្រះរាជអាជ្ញា ដែលតាមអត្ថន័យនៃពាក្យនេះផ្ទាល់[60] គឺជាភាគីបដិបក្ខ មិនមែនជាភាគី "គាំទ្រ" នោះឡើយ។ ដូច្នេះ សិទ្ធិដែលសហមេធាវីនាំមុខ បានអះអាងឡើង ក្នុងការដាក់សេចក្តីសង្កេតចំពោះសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញានោះ ពុំត្រូវបានគិតថាអនុលោមតាម ឬយកចេញមកពីវិធាន ២៣(១)(ក) នៃវិធានផ្ទៃក្នុងឡើយ។ អាស្រ័យហេតុនេះ សំណើនេះ ត្រូវបានបដិសេធ។

---

[59] សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំពន្យារពេល និងបន្ថែមចំនួនទំព័រលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណានៃបណ្តឹងសាទុក្ខ ឯកសារ F3/3 ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១១ ("យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូល (...) បង្គាប់ថា រាល់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ត្រូវដាក់មិនឲ្យហួស [ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៤]" សេចក្តីបញ្ជាក់បន្ថែម)។

[60] សូមមើល Black's Law Dictionary, 9th ed., Thomson Reuters, 2009 ទំព័រ ១៤២៦ (ដែលកំណត់និយមន័យពាក្យ "respondent (ចុងបណ្តឹងសាទុក្ខ)" ថា "១. ភាគីដែលត្រូវបានគេប្តឹងសាទុក្ខ, (...) ២. ភាគីដែលត្រូវបានគេដាក់ញត្តិ ឬសំណើប្រឆាំង")។ Oxford Dictionary of Law, 5th ed., Oxford University Press, 2003, ទំព័រ ៤៣១ (កំណត់និយមន័យនៃពាក្យ respondent (ចុងបណ្តឹងសាទុក្ខ) ថាជា "ភាគីចុងចម្លើយនៅក្នុងបណ្តឹងសាទុក្ខ ឬញត្តិ")។

01049811



## ផ្នែកសម្រេចសេចក្ដី

២៤. យោងតាមសំអាងខាងលើ **អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា៖**

**ទទួលយក**ផ្នែកខ្លះនៃសំណើ,

**អនុញ្ញាត**ឱ្យសហមេធាវីនាំមុខដាក់សារណាតបរួមរបស់ខ្លួន ឆ្លើយតបទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី ក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីសារណាតបរួមណាមួយមុនគេជាភាសាអង់គ្លេស ឬភាសាបារាំង ឬភាសាខ្មែររបស់សហព្រះរាជអាជ្ញា,

**អនុញ្ញាត**ឱ្យសហមេធាវីនាំមុខដាក់សារណាតបរួមរបស់ខ្លួនជាភាសាអង់គ្លេស ឬភាសាបារាំងជាមុនសិន បន្ទាប់មកត្រូវដាក់សំណៅជាភាសាខ្មែរឱ្យបានឆាប់រហ័សបំផុត អនុលោមតាមមាត្រា ៧.២ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ,

**បដិសេធ**សំណើរបស់សហមេធាវីនាំមុខស្នើសុំឱ្យទទួលស្គាល់សិទ្ធិរបស់ខ្លួនក្នុងការដាក់សារណាបញ្ជាក់ពីគោលជំហររបស់ខ្លួនទៅលើសារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា,

**ប្រកាសថា** នៅក្នុងដីកាកំណត់កាលបរិច្ឆេទសវនាការបណ្ដឹងសាទុក្ខ អង្គជំនុំជម្រះ ត្រូវពិចារណាលើសំណើរបស់ នួន ជា ស្នើសុំពេលវេលាបន្ថែមទៀត ដើម្បីរៀបចំទឡ្ហីករណ៍ផ្ទាល់មាត់។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ២០១៤

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**